※本文の複製、転載、改変、再配布を禁止します。

<សំនួរសំរាប់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម>

# 【1】សំនួរពាក់ព័ន្ធនឹងសិទ្ធិដាក់ពាក្យ

## I. អំពីរចនាសម្ព័ន្ធនៃនាយកដ្ឋាន

**1.**

តើមន្ត្រីកាន់កាប់បញ្ជីសំរាប់ប្រការនីយបត្រតក្កកម្មនិងគំនូរឧស្សាហកម្មមានប៉ុន្មាននាក់? ត្រូវបណ្តុះបណ្តាលយ៉ាងដូចម្តេច? មន្ត្រីទាំងឡាយនោះ ធ្លាប់ឆ្លងកាត់កម្មសិក្សានៅក្រៅប្រទេសដែរ?

**2.**

បានលឺថានៅប្រទេសកម្ពុជាមានករណីផ្តល់ប្រការនីយបត្រតក្កកម្មលើកទី១ នៅខែឧសភាឆ្នាំ២០១៥កន្លងមក។ សូមជួយបង្ហាញពីវិស័យបច្ចេកទេសនៃប្រការនីយបត្រតក្កកម្មនិងដំណើររហូតដល់បានផ្តល់នោះផង។

**3.**

យោងតាមសេចក្តីប្រកាសសារព័ត៌មានរបស់ទីភ្នាក់ងារប្រការនីយបត្រតក្កកម្មប្រទេសសឹង្ហបូរីបា

※本文の複製、転載、改変、再配布を禁止します。

នដឹងថា គេបានចុះ Memorandum of Understanding ជាមួយនាយកដ្ឋានរបស់លោក លោកស្រី។ បើយោងតាម Memorandumនេះ ថាតើត្រូវផ្ដល់តាមនីតិវិធីយ៉ាងដូចម្ដេច?

4.

ទាំងប្រការនីយបត្រតក្កកម្ម ទាំងវញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ទាំងគំនូរឧស្សាហកម្ម ថាតើចំណាយពេលប៉ុន្មានរហូតដល់បានមានសិទ្ធិ។

5.

ថាតើប្រើប្រាស់នូវការពិនិត្យរបស់ក្រៅប្រទេសយ៉ាងដូចម្ដេច (ការប្រើDBរវាងទីភ្នាក់ងារប្រការនីយបត្រតក្កកម្មស្នើអោយអ្នកដាក់ពាក្យបញ្ជូនជាដើម)?

6.

ថាតើប្រទេសកម្ពុជាមានផែនការធ្វើការពិនិត្យជាក់លាក់ដែររឺទេ? ថាបានត្រៀមរៀបចំស្តង់ដារពិនិត្យដែររឺទេ? បើមាននោះតើមានការបើកចំហរដែររឺទេ?

※本文の複製、転載、改変、再配布を禁止します。

# 【2】 ប្រការផ្សេងៗ

## I. អំពីមូលដ្ឋានទិន្នន័យData Base

**7.**

ចំពោះសំណុំលិខិតស្នើសុំប្រការនីយបត្រតក្កកម្ម

រឺប្រការនីយបត្រតក្កកម្មដែលផ្តល់ហើយនៅប្រទេសកម្ពុជា

តើមានព្រឹត្តិបត្រផ្លូវការត្រូវចេញដែររឺទេ?                    បើគ្មានព្រឹត្តិបត្រចេញ

ថាតើបើកចំហរក្នុងលក្ខណះយ៉ាងដូចម្តេច?

ម្យ៉ាងទៀតគេអាចពិនិត្យមើលនូវព្រឹត្តិបត្របានដែររឺទេ?  បើមានផែនការរៀបចំមូលដ្ឋានទិន្នន័យ

Data Base ដែលជាទិន្នន័យអេឡិចត្រូនិក សូមជួយណែនាំ។

## II. អំពីប្រព័ន្ធច្បាប់

**8.**

សូមបង្ហាញពីច្បាប់រឺប្រកាសដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញានាពេលបច្ចុប្បន្ន។

## III. អំពីសិទ្ធិអនុវត្តដោយបញ្ញា

**9.**

※本文の複製、転載、改変、再配布を禁止します。

អំពីសិទ្ធិអនុវត្តដោយបញ្ញា

មានចែងមាត្រា៥៦ដល់មាត្រា៦៣នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្មនិងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម

ថាតើមាននីតិវិធីដាក់ពាក្យពីសំណាក់អ្នកមានបំណងអនុវត្តទេ?

រឺមួយក៏វាត្រូវកំណត់ដោយរដ្ឋាភិបាល?

**10.**

ករណីដែលអាជីវកម្មរបស់ម្ចាស់សិទ្ធិប្រការនីយបត្រតក្កកម្ម ”មិនពេញលេញ”

នោះសំដៅទៅលើករណីយ៉ាងដូចម្តេច?

# IV. អំពីសិទ្ធិការប្រើប្រាស់មុន

**11.**

នៅក្នុងមាត្រា៤៤នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម

និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម

មានចែងអំពីសិទ្ធិប្រើប្រាស់មុន។ សូមបង្ហាញពីព្រំដែនដែលទទួលស្គាល់ពីសិទ្ធិប្រើប្រាស់មុន

និងនីតិវិធីចាំបាច់សំរាប់អះអាំងពីសិទ្ធិប្រើប្រាស់មុន។

※本文の複製、転載、改変、再配布を禁止します。

# V. អំពីតក្កកម្មតាមករណីយកិច្ច

## 12.

សូមបង្ហាញពីករណីជាក់លាក់ក្នុងការអនុវត្តន៍នូវការស្នងបន្តតក្កកម្មតាមករណីយកិច្ច រឺការលើកទឹកចិត្តតក្កកម្មផង។

ក្នុងករណីពុំបញ្ជាក់ពីវិធីចាត់ការលើតក្កកម្មតាមករណីយកិច្ចនៅក្នុងកិច្ចសន្យាការងារក៏ដោយ ថាតើតក្កកម្មតាមករណីយកិច្ចនោះ ត្រូវចាត់ទុកថាជារបស់អ្នកជួលដែររឺទេ?

## 13.

យល់ថា តក្កកម្មដែលកើតនៅព្រះរាជាណាចក្រកម្ពុជា មិនចាំបាច់ដាក់ពាក្យសុំនៅប្រទេសកម្ពុជាទេមែនទេ?

# VI. អំពីសិទ្ធិតំណាងភ្នាក់ងារ

## 14.

យោងតាមមាត្រា១១៦នៃច្បាប់ស្ដីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ក្នុងករណីបុគ្គលរឺនីតិបុគ្គលដែលស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជាជាអ្នកដាក់ពាក្យ ត្រូវតែមានតំណាងជាភ្នាក់ងារដែលមានទីលំនៅនិងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រ

※本文の複製、転載、改変、再配布を禁止します。

កម្ពុជា។ ថាតើភ្នាក់ងារនោះត្រូវមានចុះបញ្ជីដែរឬទេ? សូមបង្ហាញពីវិធីចុះបញ្ជី ក៏ដូចជាកម្មវិធីកម្មសិក្សាវិជ្ជាជីវៈ។

## VII. អំពីប្រការនីយបត្រតក្កកម្មលើផលិតផលឱសថ

### 15.

ចំពោះផលិតផលឱសថមិនត្រូវការពារដោយប្រកាសនីយបត្រតក្កកម្មនាពេលសព្វថ្ងៃ ដោយយោងតាមមាត្រា១៣៦នៃច្បាប់ស្តីពីប្រការនីយបត្រតក្កកម្ម និងវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍និងគំនូរឧស្សាហកម្ម ចុះប្រការនីយបត្រតក្កកម្មវត្ថុធាតុលើធាតុផ្សំ រឺប្រការនីយបត្រតក្កកម្មវិធីផលិត ក៏គ្មានអនុភាពទៅលើផលិតផលឱសថដែរ? ម្យ៉ាងទៀតយើងអាចយល់ឃើញថា ចាប់ពីថ្ងៃទី១ខែមករាឆ្នាំ២០១៦ទៅ ប្រការនេះត្រូវលប់ចោល ហើយអនុភាពនៃប្រការនីយបត្រតក្កកម្មផ្តល់លើឱសថវិញមែនទេ? អាចមានការពន្យាកាលបរិច្ឆេទខាងលើដែររឺអត់?